# ការវិភាគ

## របស់ព្រះតេជព្រះគុណហុក-សាវណ្ណ អំពីអាកប្បកិរិយារបស់រាជរដ្ឋាភិបាលខ្មែរ ចំពោះខ្មែរកម្ពុជាក្រោម

web site: hoksavann.org

ថ្ងៃទី១៦ មីនា ២០០៦

មាត្រា៣៣នៃរដ្ឋធម្មនុញ្ញខ្មែរបច្ចុប្បន្នបានចែងថា «ប្រជាពលរដ្ឋខ្មែរដែលកំពុងរស់នៅឯបរទេស ត្រូវបានរដ្ឋគាំពារ» ។ ធម្មនុញ្ញនេះបានត្រូវអនុម័ត ហើយលោកសឹន-សានបានចុះហត្ថលេខាឲ្យប្រើនៅភ្នំពេញ ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ ។ តាំងពីពេលនោះរហូតមកដល់ឆ្នាំ២០០៦នេះ រាជរដ្ឋាភិបាលខ្មែរចំនួនជិតចប់៣អាណត្តិហើយ ពុំអើពើនិងធ្វើសកម្មភាពបែបណាមួយ ជួយខ្មែរកម្ពុជាក្រោម ដែលជាខ្មែរឲ្យចេញផុតពីការគាបសង្កត់ និងបំបិទសិទ្ធិគ្រប់បែបយ៉ាង របស់រដ្ឋាភិបាលវៀតណាមឡើយ ។ ទឹកដីខ្មែរកម្ពុជាក្រោម ដែលពីដើមជាទឹកដីរបស់រាជាណាចក្រកម្ពុជា បានត្រូវសភាបារាំងប្រគល់ឲ្យវៀតណាម តាមច្បាប់លេខ៧៣៣ នៅថ្ងៃ៤ មិថុនា ១៩៤៩ ដោយដាក់ខ្មែរក្រោមក្នុងរបបគ្រប់គ្រងវៀតណាម ។ នេះជាអំពើអយុត្តិធម៌ របស់អាណានិគមនិយមបារាំង ដែលរំលោភលើសិទ្ធិរបស់រាជាណាចក្រកម្ពុជាជាម្ចាស់ទឹកដី ។ ទំហំកម្ពុជាក្រោមមាន៦៧,០០០គ.ម.២ ឯកសារខ្លះថាមាន ៦៩,៦០០ គ.ម.២ ។ បច្ចុប្បន្ននេះកម្ពុជាក្រោមមានប្រជាពលរដ្ឋ៨លាននាក់ ខ្លះថាមាន១០លាននាក់ ខ្លះថាមានរហូតដល់១២លាននាក់ ដែលជិតស្មើនឹងប្រជាពលរដ្ឋនៅរាជាណាកម្ពុជាដែរ ។ ខ្មែរកម្ពុជាក្រោមបានត្រូវចែកជា២១ខេត្ត ជិតស្មើនឹងខេត្តនៅកម្ពុជាកណ្តាលដែរ ហើយមានវត្តព្រះពុទ្ធសាសនាចំនួន៥០០វត្ត ។ បងប្អូនខ្មែរកម្ពុជាក្រោមនៅតែរក្សាអត្តសញ្ញាណជាខ្មែរ គោរពព្រះពុទ្ធសាសនាយ៉ាងខ្លាំងក្លា ហើយខំប្រឹងប្រែងរក្សាប្រពៃណីទំនៀមទំលាប់ អក្សរសាស្ត្រជាតិខ្លួនយ៉ាងម៉ឺងម៉ាត់ ទោះបីអាជ្ញាធរវៀតណាម ទាំងវៀតណាមសេរី ទាំងវៀតណាមកុម្មុយនិស្ត ធ្វើទុក្ខបុកម្នេញយ៉ាងណាក៏ដោយ ។

បងប្អូនខ្មែរកម្ពុជាក្រោមខ្លះមានភ័ព្វសំណាងបានមករស់នៅបរទេស បានចោទ

វៀតណាមថា កាលពីអតីតកាល វៀតណាមបានដុតខ្មែរទាំងរស់ក្នុងជង្រុកស្រូវ, បានកប់ខ្មែរទាំងរស់ ធ្វើជាមុមជើងក្រាន នៅពេលខ្មែរក្តៅឈឺចុកចាប់ គេស្រែកថា កុំរើប្រយ័ត្នកំពប់តែអុងជាដើម ។ មកដល់បច្ចុប្បន្ននេះទៀត អាជ្ញាធរវៀតណាមបានបំបិទមិនឲ្យខ្មែររៀនអក្សរខ្មែរ បំបិទមិនឲ្យខ្មែររក្សាប្រពៃណីទំនៀមទំលាប់របស់ខ្លួនឲ្យបានពេញលេញ ព្រមទាំងរឹតត្បិតក្នុងសកម្មភាពគោរពព្រះពុទ្ធសាសនា ដូចជា តាមព្រះវិន័យព្រះពុទ្ធសាសនា ពិធីបុណ្យកឋិន អាចធ្វើបានចំនួន២៩ថ្ងៃ គឺចំនួន ១ខែ ប៉ុន្តែអាជ្ញាធរវៀតណាមឲ្យធ្វើគ្រប់វត្តទាំងអស់តែ១ថ្ងៃ ។ បងប្អូនកម្ពុជាក្រោម ក្នុងពេលថ្មីៗនេះបានពោលថា មានបងប្អូនខ្មែរក្រោមរាប់រយពាន់នាក់ នៅក្នុងខេត្តមួយ បានងងឹតភ្នែកពុំដឹងជាបណ្តាលមកពីហេតុអ្វី ។ មានដីស្រែខ្លះរបស់បងប្អូនខ្មែរកម្ពុជាក្រោម បានត្រូវវៀតណាមធ្វើផែនការរឹបយក ។ សូម្បីជំនួយបរទេសដែលជួយទៅវៀតណាម ដែលឲ្យជួយជនជាតិភាគតិច ក៏ពុំឃើញយកទៅជួយខ្មែរកម្ពុជាក្រោម តាមបំណងរបស់ម្ចាស់ជំនួយឡើយ ។

កាលពីអំឡុងខែសីហាឆ្នាំ២០០៥ ដោយមានការភ័យខ្លាចពីអាជ្ញាធរវៀតណាមចាប់ខ្លួន បងប្អូនខ្មែរកម្ពុជាក្រោម ដែលមានព្រះសង្ឃ២១អង្គ និងប្រជាពលរដ្ឋ៥២នាក់ មកពីខេត្ត៥គឺ ខេត្តពលលាវ, ខេត្តមាត់ជ្រូក, ខេត្តទឹកខ្មៅ, ខេត្តឃ្លាំង និងខេត្តព្រះត្រពាំង បានរត់ភៀសខ្លួនមកភ្នំពេញប្រទេសកម្ពុជា ហើយសុំឲ្យស្នងការជាន់ខ្ពស់សហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន (UNHCR) នៅកម្ពុជាទទួលស្គាល់ជាជនភៀសខ្លួននយោបាយ តែត្រូវរាជរដ្ឋាភិបាលខ្មែររារាំងមិនទទួលស្គាល់ ។ ជាញឹកញាប់ ក្រុមអ្នកសង្កេតការណ៍បានរិះគន់ចំពោះរាជរដ្ឋាភិបាលខ្មែរថា ខ្មែរម្ចាស់ស្រុកចូលដីខ្មែរ ត្រូវបានរាជរដ្ឋាភិបាលខ្មែរប្រើកម្លាំងដេញសំពង តែបើយួនចូលស្រុកខ្មែរ រាជរដ្ឋាភិបាលខ្មែរទទួលស្វាគមន៍ដៃពីរ ហើយជួយសំរួលឲ្យរស់នៅបានសុខស្រួលថែមទៀត ។ បានសេចក្តីថា ខ្មែរកម្ពុជាក្រោមមកដីខ្មែរកណ្តាល ត្រូវអាជ្ញាធរខ្មែរធ្វើបាប តែបើយួនចូលមកខុសច្បាប់រាល់ថ្ងៃ បែរជាត្រូវបានរាជរដ្ឋាភិបាលខ្មែរស្វាគមន៍ដោយរីករាយ និងធ្វើអត្តសញ្ញាណប័ណ្ណឲ្យទៀត និងទទួលស្គាល់យួនជាជាតិខ្មែរជាស្វ័យប្រវត្តិ ដែលសព្វថ្ងៃតាមអ្នកស្រាវជ្រាវជនអន្តោប្រវេសន៍ខ្មែរថា យួនអន្តោប្រវេសន៍នៅប្រទេសខ្មែរសព្វថ្ងៃ មានចំនួន៤លានកន្លះ ហើយមានសិទ្ធិបោះឆ្នោតនៅកម្ពុជាចំនួន៤០ភាគរយ ក្នុងចំណោមអ្នកបោះឆ្នោតមានតែ៥លាននាក់ ។ បងប្អូនខ្មែរកម្ពុជាក្រោមត្អូញត្អែរថា ខ្មែរក្រោមខ្លះមករស់នៅកម្ពុជាជាយូរមកហើយបានសុំប័ណ្ណអាជ្ញាធរខ្មែរ ដើម្បីឲ្យមានសិទ្ធិត្រឹមត្រូវតាមច្បាប់ តែត្រូវអាជ្ញាធរខ្មែរពុំសូវយកចិត្តទុកដាក់ ពុំងាយធ្វើប័ណ្ណឲ្យឡើយ ចេះតែសួរដេញដោលពីស្រុកកំ-ណើត ។ នៅកម្ពុជាក្រោមត្រូវយួនធ្វើបាបភ័យខ្លាចរត់មករស់នៅកម្ពុជាកណ្តាល ក៏ត្រូវអាជ្ញាធរខ្មែរធ្វើបាបទៀត ។ រដ្ឋាភិបាលវៀតណាម គេយកចិត្តទុកដាក់ណាស់ចំពោះជនជាតិគេនៅបរទេស ដូចជនជាតិគេមានកើតហេតុអ្វីមួយប៉ះពាល់ដល់ជនជា

តិគេនៅប្រទេសកម្ពុជា រដ្ឋាភិបាលវៀតណាម គេស្រែកធ្វើអន្តរាគមន៍ភ្លាម ចំណែករាជរដ្ឋាភិបាលខ្មែរវិញ ទោះបីខ្មែរកម្ពុជាក្រោមមានទុក្ខវេទនា ដោយអាជ្ញាធរវៀតណាមធ្វើបាប មានចាប់ព្រះសង្ឃដាក់គុក និងធ្វើគតដោយសម្ងាត់ក្តី ក៏រាជរដ្ឋាភិបាលខ្មែរគ្មានអើពើធ្វើអន្តរាគមន៍សោះឡើយ ។ ចំណែកឯកអគ្គរាជទូតខ្មែរប្រចាំប្រទេសវៀតណាម ក៏គ្មានបានបំពេញនាទីរបស់ខ្លួន ជួយដោះស្រាយសេចក្តីទុក្ខវេទនារបស់បងប្អូនខ្មែរកម្ពុជាក្រោមសោះឡើយ ទោះបីពួកគេទៅពឹងឲ្យជួយ ក៏បុគ្គលិកទូតទាំងនោះពុំហ៊ានធ្វើអ្វីឡើយ ក្រៅពីចាំស្តាប់បញ្ជាពីអង្គការលើ គឺរាជរដ្ឋាភិបាលនៅភ្នំពេញតែប៉ុណ្ណោះ ។ កាលពីឆ្នាំ២០០៥ ព្រះសង្ឃខ្មែរកម្ពុជាក្រោមពីរព្រះអង្គចូលមកប្រទេសកម្ពុជា ត្រូវអាជ្ញាធរប៉ូលិសខ្មែរចាប់ផ្សឹក រួចដេញទៅប្រទេសវៀតណាមវិញ ។ គេនៅតែងឿងឆ្ងល់ថា តើរាជរដ្ឋាភិបាលខ្មែរ សព្វថ្ងៃនេះតំណាងឲ្យផលប្រយោជន៍ខ្មែរឬទេ ជាមួយប្រទេសវៀតណាម ។ តួយ៉ាងក្រសួងមហាផ្ទៃនៃរាជាណាចក្រកម្ពុជាបានអនុញ្ញាតច្បាប់សមាគម ឲ្យជនជាតិវៀតណាម១៨ខេត្តក្នុងប្រទេសខ្មែរ ធ្វើសកម្មភាពបំរើសហគមវៀតណាមបានដោយសេរី ផ្ទុយទៅវិញរដ្ឋាភិបាលវៀតណាម ពុំអនុញ្ញាតឲ្យខ្មែរកម្ពុជាក្រោមបង្កើតសមាគមនិងធ្វើសកម្មភាពបំរើសហគមខ្មែរកម្ពុជាក្រោមឡើយ ។ រាជរដ្ឋាភិបាលខ្មែរដឹងរឿងនេះ ប៉ុន្តែពុំបានធ្វើអន្តរាគមន៍ជួយខ្មែរកម្ពុជាក្រោមឡើយ ។ មានខ្មែរខ្លះមានការព្រួយបារម្ភថា សព្វថ្ងៃនេះសមាគមវៀតណាមនៅកម្ពុជា បានចាត់កម្មវិធីរៀនអក្សរខ្មែរ ។ តាមទស្សនៈអាត្មាវិញ ពុំគួរព្រួយបារម្ភអំពីជនជាតិវៀតណាមរៀនអក្សរខ្មែរឡើយ ប៉ុន្តែគួរព្រួយបារម្ភដូច្នេះវិញ តើវៀតណាមទាំងនោះ ចូលមកកម្ពុជាស្របច្បាប់ឬខុសច្បាប់ ។

ចាប់បីសភាបារាំងប្រគល់ទឹកដីខ្មែរកម្ពុជាក្រោមឲ្យទៅវៀតណាមដោយអយុត្តិធម៌នៅឆ្នាំ១៩៤៩មក គ្មានឃើញរាជរដ្ឋាភិបាលខ្មែរអាណត្តិក្រោយៗ មកទាមទារទឹកដីដែលបាត់បង់នោះត្រឡប់មកវិញឲ្យបានខ្លាំងក្លាឡើយ ។ ដោយគ្មានសង្ឃឹមថា ខ្មែរកណ្តាលនឹងជួយខ្លួន បងប្អូនខ្មែរកម្ពុជាក្រោមបានខំប្រឹងប្រែងដោយខ្លួនឯងដើម្បីទាមទារសិទ្ធិជាជនជាតិភាគតិចនៅលើទឹកដីកំណើតរបស់ខ្លួន ។ ការខំប្រឹងប្រែងរបស់ខ្មែរកម្ពុជាក្រោមបានទទួលលទ្ធផលខ្លះ កាលពីថ្ងៃ១៥កក្កដា២០០១ ខ្មែរកម្ពុជាក្រោមបានក្លាយជាសមាជិកអង្គការនៃប្រជាជាតិគ្មានគេតំណាង (Unpresented Nations and People Organization - UNPO) ។ អង្គការនៃប្រជាជាតិគ្មានគេតំណាងទាំងមូលមាន៥២ប្រទេស តំណាងឲ្យប្រជាពលរដ្ឋជាង១០០លាននាក់ពាសពេញពិភពលោក ។ ប្រទេសដែលគ្នាតំណាងក្នុងអង្គការសហប្រជាជាតិមានប្រទេសខ្លះបានទទួលឯករាជ្យហើយ ប្រទេសខ្លះកំពុងធ្វើសកម្មភាពបង្កើតរដ្ឋាភិបាលក្រៅប្រទេស ។ សព្វថ្ងៃនេះ វៀតណាមកំពុងតែព្យាយាម ធ្វើឲ្យខ្មែរកម្ពុជាក្រោមជាជនជាតិវៀតណាម ដោយលុបបំបាត់ជាជនជាតិភាគតិច ។ យើងនៅរង់ចាំមើលការតស៊ូរបស់ខ្មែរកម្ពុជាក្រោម ដោយសាមគ្គីគ្នា ដើម្បីទាមទារសិទ្ធិរបស់ខ្លួន

តើមានលទ្ធផលជាវិជ្ជមានបែបណាទៅអនាគត ។ យើងនៅចាំថា កាលពីប៉ុន្មានខែមុននេះ វៀតណាមបានបង្ខំឲ្យរដ្ឋាភិបាលខ្មែរ ទទួលស្គាល់សន្ធិសញ្ញាព្រំដែនខុសច្បាប់កាលពីឆ្នាំ១៩៨៥ ឲ្យទៅជាស្របច្បាប់ រហូតដល់មានការចាប់អ្នកប្រឆាំងដាក់ក្នុងពន្ធនាគារ ដោយមានបញ្ហាខ្មែរកម្ពុជាក្រោមកំរើកឡើង នេះជាកត្តាសំខាន់មួយរបស់វៀតណាម ។

ខ្មែរកម្ពុជាកណ្តាលក៏ដូចជាខ្មែរកម្ពុជាក្រោម សុទ្ធតែជាអ្នកគោរពព្រះពុទ្ធសាសនា ចង់រស់នៅដោយសន្តិភាពជាមួយប្រជាជាតិក្នុងលោក ជាពិសេសប្រទេសនៅភូមិផងរបងជាមួយ ។ ព្រះពុទ្ធបានប្រៀបប្រដៅពុទ្ធបរិស័ទរបស់ព្រះអង្គ កុំឲ្យបៀតបៀនអ្នកដទៃ ប្រទេសដទៃ តែព្រះពុទ្ធឲ្យការពារសិទ្ធិរបស់ខ្លួន ទប់ទល់នឹងការឈ្លានពានរបស់អ្នកដទៃដោយមធ្យោបាយសន្តិវិធី ។ យើងសូមឲ្យជនជាតិវៀតណាមដែលធ្លាប់រស់នៅប្រទេសកម្ពុជាជាយូរមកហើយ មានជនជាតិវៀតណាមខ្លះស្រឡាញ់វប្បធម៌ខ្មែរផង សូមឲ្យជនជាតិវៀតណាមទាំងនោះ រស់នៅដោយសុខសាន្តក្នុងប្រទេសកម្ពុជាជាមួយជនជាតិខ្មែរ ស្របតាមច្បាប់ជាតិនិងអន្តរជាតិ ។ ចំពោះអ្នកចូលមកកម្ពុជាដោយខុសច្បាប់ ត្រូវតែអនុវត្តតាមច្បាប់អន្តោប្រវេសន៍ ។ យើងមិនយល់ស្របនឹងការតក់ស្លុតចំពោះរបបមុន មានរបបខ្មែរក្រហមជាដើម បានកាប់សម្លាប់ជនស៊ីវិលវៀតណាមស្លូតត្រង់អស់ជាច្រើន ដោយគោលដៅឃោឃៅមិនគួរឲ្យកើតមាននូវអំពើអមនុស្សធម៌បែបនេះតទៅទៀតទេ អំពើបែបនេះត្រូវតែផ្តន្ទាទោសតាមច្បាប់ ។

បើរាជរដ្ឋាភិបាលខ្មែរបច្ចុប្បន្ន ដែលឲ្យតម្លៃទៅវៀតណាមថាជាអ្នកមានគុណមិនហ៊ានធ្វើអន្តរាគមន៍ ព្រោះខ្លាចប៉ះពាល់ដល់វៀតណាម ឬធ្វើឲ្យវៀតណាមអាក់អន់ចិត្ត ចំពោះបញ្ហាខ្មែរកម្ពុជាក្រោមនេះ ក៏ពុំគួរធ្វើឲ្យពួកគេមានទុក្ខថែមទៀតនៅប្រទេសកម្ពុជា ដូចសុភាសិតខ្មែរថា ចុះទឹកក្រពើឡើងលើខ្លា ។ បានសេចក្តីថា បើរាជរដ្ឋាភិបាលខ្មែរមិនហ៊ានជួយខ្មែរកម្ពុជាក្រោមនៅក្នុងប្រទេសវៀតណាម ក៏គួរជួយខ្មែរកម្ពុជាក្រោមខ្លះ ដែលបានមករស់នៅក្នុងប្រទេសកម្ពុជា ដែលស្ថិតនៅក្រោមអំណាចខ្លួន ឲ្យមានសិទ្ធិរស់នៅដូចខ្មែរទូទៅ ។ ភាពជាអ្នកដឹកនាំដ៏ខ្ពង់ខ្ពស់ គេត្រូវតែធ្វើអ្វីទាំងអស់ ដើម្បីការពារសិទ្ធិប្រជាពលរដ្ឋទាំងក្នុងប្រទេសនិងក្រៅប្រទេស ទោះបីប៉ះពាល់ដល់អំណាចរបស់ខ្លួនក៏ដោយ ។ កុំឲ្យគេចោទថា ជនជាតិវៀតណាមចូលមកកម្ពុជា អាជ្ញាធរខ្មែរទទួលស្វាគមន៍ ហើយមានជនជាតិវៀតណាមខ្លះសម្រួលធ្វើប័ណ្ណសញ្ជាតិឲ្យទៀត ចំណែកខ្មែរកម្ពុជាក្រោម ដែលជាខ្មែរចូលមកកម្ពុជាវិញ អាជ្ញាធរខ្មែរសំដែងអាការៈប្រងើយកន្តើយ មិនជួយសម្រួលខាងផ្លូវច្បាប់ឲ្យឆាប់រហ័សឡើយ ។ តាមការសង្កេត ជនជាតិខ្មែរចូលទៅប្រទេសវៀតណាម ក្រសួងអន្តោប្រវេសន៍វៀតណាមអនុវត្តច្បាប់យ៉ាងតឹងតែង ប៉ុន្តែបើជនជាតិវៀតណាមចូលមកកម្ពុជាវិញ ចូលបានដោយងាយ ពុំសូវតឹងតែងខាងផ្លូវច្បាប់ឡើយ ។ ប្រទេស

កម្ពុជាក៏ដូចជាប្រទេសប្រជាធិបតេយ្យនានាក្នុងលោកដែរ ដែលមានច្បាប់រដ្ឋធម្មនុញ្ញជាច្បាប់កំពូលរបស់ប្រទេស ហើយមុននឹងចូលទៅកាន់តំណែងស្ថាប័នកំពូលគឺ ព្រះមហាក្សត្រ រដ្ឋសភា និងរដ្ឋាភិបាល បានធ្វើសច្ចាប្រណិធានគោរពតាមច្បាប់រដ្ឋធម្មនុញ្ញ ។ ឥឡូវនេះ រាជរដ្ឋាភិបាលខ្មែរបច្ចុប្បន្ន មិនបានអនុវត្តតាមមាត្រា៣៣នៃរដ្ឋធម្មនុញ្ញ ដែលចែងថា «ប្រជាពលរដ្ឋខ្មែរ ដែលកំពុងរស់នៅឯបរទេស ត្រូវបានរដ្ឋគាំពារ» ៕៚

❑ ❑

❑